ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំប្រទេសជប៉ុន

# សេចក្តីប្រកាសព័ត៌មាន

## ឯកឧត្តមជុំ សុន្ទរី ជួបសម្តែងការគួរសមការជាមួយ អគ្គលេខាធិការ នៃសម្ព័ន្ធមិត្តភាពសភាជប៉ុន-កម្ពុជា

តូក្យូ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៦ **ឯកឧត្តម ជុំ សុន្ទរី** ឯកអគ្គរាជទូតតែងតាំងនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសជប៉ុន បានចូលជួបសម្តែងការគួសមជាមួយ **ឯកឧត្តម KIUCHI Minoru រដ្ឋមន្ត្រីទទួលបន្ទុកយុទ្ធសាស្ត្រកំណើនរបស់ជប៉ុន សមាជិកសភាតំណាងរាស្ត្រ និងជាអគ្គលេខាធិការ នៃសម្ព័ន្ធមិត្តភាពសភាជប៉ុន-កម្ពុជា** នៅអគាររដ្ឋាភិបាលកណ្តាល។

ក្នុងជំនួបនេះ **ឯកឧត្តមឯកអគ្គរាជទូត** បានសម្តែងការកោតសរសើរយ៉ាងជ្រាលជ្រៅចំពោះកិច្ចខិតខំប្រឹងប្រែងយូរអង្វែងរបស់សម្ព័ន្ធមិត្តភាពសភាជប៉ុន-កម្ពុជា ក្នុងការលើកកម្ពស់មិត្តភាព និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។ ឯកឧត្តមបានលើកឡើងពីសារៈសំខាន់ដែលកម្ពុជាផ្តល់ចំពោះការទូតសភា ដែលជាសសរគ្រឹះសំខាន់មួយនៃទំនាក់ទំនងទ្វេភាគី ហើយបានបញ្ជាក់ពីតួនាទីដ៏សំខាន់របស់សម្ព័ន្ធក្នុងការលើកស្ទួយការយល់ដឹងគ្នាទៅវិញទៅមក ជំរុញការផ្លាស់ប្តូររវាងសមាជិកសភា និងលើកកម្ពស់ទំនាក់ទំនងប្រជាជន និងប្រជាជន។

**ឯកឧត្តមឯកអគ្គរាជទូត** បានសំដែងការពេញចិត្តចំពោះភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយរវាងកម្ពុជា និងជប៉ុន ដែលបង្ហាញពីការជឿទុកចិត្តជ្រាលជ្រៅ និងកិច្ចសហប្រតិបត្តិការដ៏រឹងមាំលើវិស័យជាច្រើន រួមមាន ការសន្ទនានយោបាយ កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ពាណិជ្ជកម្ម និងវិនិយោគ ការអភិវឌ្ឍធនធានមនុស្ស សន្តិសុខ និងការផ្លាស់ប្តូរវប្បធម៌។ ឯកឧត្តមបានបញ្ជាក់ឡើងវិញពីការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែមទៀត រួមទាំងតាមរយៈការបង្កើនការផ្លាស់ប្តូរសភា ដើម្បីធ្វើឱ្យភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយកម្ពុជា-ជប៉ុន កាន់តែស៊ីជម្រៅ។

**ឯកឧត្តមឯកអគ្គរាជទូត** បានជម្រាបជូន**ឯកឧត្តម** KIUCHI Minoru អំពីស្ថានភាពបច្ចុប្បន្នតាមព្រំដែនកម្ពុជា-ថៃ ដោយបានបញ្ជាក់ឡើងវិញពីការប្តេជ្ញាចិត្តយ៉ាងមុឹងម៉ាត់របស់កម្ពុជា ក្នុងការអត់ធ្មត់ ការដោះស្រាយដោយសន្តិវិធី និងការប្រើប្រាស់យន្តការទ្វេភាគីដែលមានស្រាប់ ជាពិសេសគណៈកម្មការព្រំដែនរួម (JBC) ដែលជាយន្តការស្របច្បាប់សម្រាប់ដោះស្រាយបញ្ហាព្រំដែន។ ឯកឧត្តមក៏បានសម្តែងការកោតសរសើរចំពោះការយល់ដឹង ជំហរប្រកបដោយភាពស្ថាបនា និងជំនួយមនុស្សធម៌របស់ជប៉ុនដែលបានផ្តល់ជូនប្រជាពលរដ្ឋកម្ពុជា ដែលរងផលប៉ះពាល់ផងដែរ៕

ថ្ងៃអង្គារ ១៣កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
តូក្យូ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៦

8-6-9 AKASAKA, MINATO-KU, TOKYO 107-0052
Tel : +81 3-5412-8521 Fax: +81 3-5412-8526
Email: camemb.jpn@mfaic.gov.kh